

ក្របខាងមុខ៖ ប្រាសាទកោះកេរ្តិ៍ស្ថិតនៅចម្ងាយប្រហែលជាងមួយរយម្ភៃគីឡូម៉ែត្រនៅភាគឦសាននៃខេត្តសៀមរាប។ យើងអាចទៅដល់ប្រាសាទនេះតាមរយៈផ្លូវជាតិ និងផ្លូវលំ ហើយប្រាសាទនេះមានផ្លូវទឹកព័ទ្ធជុំវិញ ដោយហូរចុះមកពីភ្នំក្បែរៗនោះ។ តំបន់នោះមានទំនាក់ទំនងជាមួយនឹងរជ្ជកាលព្រះបាទ ជ័យវរ្ម័នទី៤ (៩២៨ ដល់៩៤១ គ.ស) ដែលព្រះអង្គបានយាងចេញពីរាជធានី អង្គរក្នុង គ.ស ៩២១ ក្នុងគោលបំណងកសាងអំណាចរបស់ព្រះអង្គនៅក្នុងតំបន់ ឆោកគគ៌្យរ ដែលបច្ចុប្បន្ននេះត្រូវបានស្គាល់ថាជា តំបន់កោះកេរ្តិ៍។ក្រោយពេលព្រះអង្គសោយទិវង្គត ក្សត្រស្នងរាជបន្ទាប់គឺព្រះបុត្រារបស់ព្រះអង្គ ព្រះនាមរាជេន្ទ្រវរ្ម័នទី២បានកសាងរាជធានីអង្គរឡើងវិញដោយព្រះអង្គបានបោះបង់រាជធានីកោះកេរ្តិ៍នៅក្នុងសតវត្សរ៍ទី១៩។(ចម្ងាយពីប្រាសាទកោះកេរ្តិ៍ទៅកាន់ស្រុកអន្លង់វែងគឺ១៨៦គីឡូម៉ែត្រ។
រូបថត ថតដោយ អ៊ូច មករា)

រូបថតខាងលើ៖ ប្រាសាទអង្គរវត្តរបស់ប្រទេសកម្ពុជាបានក្លាយជាវិមានសាសនាដ៏ធំបំផុតរបស់ពិភពលោក។ ប្រាសាទនេះត្រូវបានសាងសង់ឡើងដោយព្រះមហាក្សត្រខ្មែរព្រះនាម សូរ្យវរ្ម័នទី២ ក្នុងដើមសតវត្សរ៍ទី១២ នៅក្នុងក្រុង យសោធរបុរៈដែលជា រាជធានីរបស់ចក្រភពអង្គរ។ (ចម្ងាយពីប្រាសាទអង្គរវត្តទៅស្រុកអន្លង់វែងគឺ១២៩គីឡូម៉ែត្រ។ រូបថតដោយ ម៉េង គីមឡុង)


គាំទ្រដោយ៖

Robert Bosch Stiftung

USAID FROM THE AMERICAN PEOPLE



THE SLEUK RITH INSTITUTE
a permanent DOCUMENTATION CENTER of CAMBODIA
មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍

វិទ្យាស្ថានស្លឹករឹត, មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍
ទូរសព្ទ៖ ៨៥៥ ១២ ៩៧០ ៤៦៥ សារអេឡិចត្រូនិច៖ truthlysokkheang@dccam.org គេហទំព័រ៖ www.d.dccam.org

សម្រាប់ពត៌មានបន្ថែម សូមទាក់ទងមកកាន់៖
បណ្ឌិត លី សុខឃាង, នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
ទូរសព្ទ៖ ៨៥៥ ១២ ៩៧ ០៤ ៦៥

ទូន ឡៃហុល, អ្នកសម្របសម្រួលគម្រោង
ទូរសព្ទ៖ ០៨៩ ៦២៩ ៥២៥


ថ្ងៃ ១ ខែ ធ្នូ ឆ្នាំ ២០១៥



វិទ្យាស្ថានស្លឹករឹតប្រកាន់យកទស្សនៈជាមូលដ្ឋាននៃបេតិកភណ្ឌវប្បធម៌ និង
សិល្បៈបែបសហសម័យរបស់ ប្រទេសកម្ពុជា មកធ្វើជាប្រភពនៃការព្យាបាលនិងការផ្សះផ្សា។

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

«សន្តិភាពមានន័យថាជាដំណេកយ៉ាងស្កប់ស្កល់មួយ ហើយក្រោយពេលភ្ញាក់ពីដំណេក អ្នកគ្មានការភ័យខ្លាចអ្វី ទាល់តែសោះ...»
ឆាំង យុ

ដោយទទួលបានជំនួយសប្បុរសពីសំណាក់មូលនិធិ The Robert Bosch Stiftung និងដោយមានកិច្ចសហការណ៍ជាមួយក្រសួងទេសចរណ៍នៃរាជរដ្ឋាភិបាលកម្ពុជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានសេចក្តីរីករាយក្នុងការជម្រាបជូនសាធារណជនស្តីពី «ដំណើរទស្សនកិច្ចសិក្សាស្តីពី សន្តិភាពអន្លង់វែង»។ មជ្ឈមណ្ឌលសន្តិភាពនេះគឺជាកិច្ចផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

កម្មវិធី «ដំណើរទស្សនកិច្ចសិក្សាស្តីពី សន្តិភាពអន្លង់វែង» នេះគឺជាគំនិតផ្តួចផ្តើមសម្រាប់ការផ្សះផ្សាក្នុងសហគមន៍ដោយមានគោលបំណងផ្សាភ្ជាប់ការបែងចែងគ្នារវាងអតីតកម្មាភិបាលខ្មែរក្រហមនៅក្នុងតំបន់តស៊ូចុងក្រោយអន្លង់វែងជាមួយនិងប្រជាជនកម្ពុជាជំនាន់ក្រោយ។ គោលបំណងកម្មវិធីនេះគឺផ្តល់ជូននូវវេទិកាអប់រំសម្រាប់ការសិក្សា( និងការបន្ធូរបន្ថយ )ជម្លោះមនុស្សជាតិ ព្រមទាំងជំរុញឲ្យមានចូលរួមរបស់ប្រជាពលរដ្ឋឲ្យបានកាន់តែទូលំទូលាយជាងមុន។

តាមរយៈការប្រើប្រាស់កិច្ចការពីមុនៗ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការអប់រំស្តីពី អំពើប្រល័យពូជសាសន៍ធ្វើជាគំរូគម្រោងដំណើរទស្សនាកិច្ចសិក្សានេះនឹងដឹកនាំសិស្សានុសិស្ស ទៅកាន់តំបន់តស៊ូចុងក្រោយខ្មែរក្រហមនៅអន្លង់វែងតាមរយៈដំណើរទស្សនកិច្ចសិក្សា៤ថ្ងៃ ក្នុងគោលបំណងបង្កលទ្ធភាពជូនដល់សិស្សានុសិស្សទាំងនោះចូលរួមក្នុងសកម្មភាពអប់រំប្រចាំថ្ងៃ ដែលតម្រូវឲ្យសិស្សានុសិស្សចេះត្រិះរិះពិចារណាបង្ហាញពីគំនិតផ្ទាល់ខ្លួន និងពិភាក្សា ម៉្យាងវិញសកម្មភាពទាំងនោះក៏ផ្តល់ឲ្យសិស្សានុសិស្សនូវឱកាសប្រាស្រ័យទាក់ទងសន្ទនា និងសួរសំនួរទៅកាន់អតីតកម្មាភិបាលខ្មែរក្រហមនិងជនរងគ្រោះដែលរស់នៅក្នុងតំបន់នោះដែរ។

កម្មវិធីនេះ មិនត្រឹមតែផ្តល់នូវការយល់ដឹងយ៉ាងទូលំទូលាយអំពីប្រវត្តិសាស្រ្តដ៏ហិង្សារបស់ប្រទេសកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានគោលដៅបង្កើតការយល់ដឹងជាមូលដ្ឋានទាក់ទងនឹងទ្រឹស្តីផ្សេងៗគ្នានៃការដោះស្រាយនិងការប្រែក្លាយជម្លោះទៀតផង។ ដំណើរទស្សនកិច្ចសិក្សានេះនឹងឆ្លើយតបទៅតាមកម្មវត្ថុរបស់ខ្លួនតាមរយៈការពិភាក្សារួមគ្នា។ ដំណើរទស្សនកិច្ចសិក្សាតាមបណ្តារមណីយដ្ឋានប្រវត្តិសាស្រ្តក្នុងតំបន់ដោយមានមគ្គុទ្ទេសន៍រួមទាំងកម្មវិធីសិក្សាដែលប្រើប្រាស់រឿងរ៉ាវផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ជាមេរៀនប្រវត្តិសាស្រ្ត និងសីលធម៌។ ដំណើរទស្សនកិច្ចសិក្សានេះនឹងធ្វើឡើងសំដៅជួយស្តារឡើងវិញសម្រាប់ជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហមដោយហេតុថាដំណើរទស្សនកិច្ចសិក្សានេះធ្វើឲ្យក្រុមទាំងពីរមានឱកាសក្នុងការឆ្លុះបញ្ចាំង និងចែករំលែកការយល់ដឹងពីបទពិសោធន៍របស់ខ្លួនក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងសម័យសង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧៩ ដល់១៩៩៨)។

ដំណើរទស្សនកិច្ចសិក្សានេះផ្អែកលើកម្មវិធីសិក្សាមួយដែលជំរុញឲ្យមានកាគិត និងមានលក្ខណៈបុគ្គល។ តាមរយៈការពិភាក្សាទល់មុខគ្នារវាងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ កម្មវិធីនេះអាចធ្វើឲ្យអ្នកចូលរួមព្យាយាមសញ្ជឹងគិតពីភាពទីទៃពីគ្នានៃបទពិសោធន៍របស់មនុស្ស (ទាំងបទពិសោធន៍បែបមនុស្សធម៌ និងអមនុស្សធម៌) អំឡុងពេលដែលមានជម្លោះនិងចលាចលសង្គម។ រឿងរ៉ាវទាំងនោះនឹងបញ្ជាក់ពីសារសំខាន់នៃការប្រព្រឹត្តរបស់មនុស្សជាតិម្នាក់ៗ និងជួយជំរុញឲ្យមានសមាសភាពជាមូលដ្ឋាននៃការប្រែក្លាយជម្លោះនិងជំនាញរបស់មនុស្ស។ ទស្សនទានមួយចំនួនដូចជាសមត្ថភាពក្នុងការឆ្លុះបញ្ចាំងការគិតប្រកបដោយសត្យានុម័ត និងចេះយោគយល់គ្នាទៅវិញទៅមក គឺជាមូលដ្ឋានគ្រឹះសម្រាប់សង្គមមានសន្តិភាព និងប្រជាធិបតេយ្យទាំងឡាយ។ គម្រោងនេះនឹងផ្តោតសំខាន់លើការយោគយល់គ្នាតាមបែបប្រវត្តិសាស្រ្ត ដែលជាគោលបំណងស្នូលរបស់គម្រោង ហើយម៉្យាងវិញទៀត សិស្សានុសិស្សដែលចូលរួមក្នុងកម្មវិធីទាំងអស់មានការទទួលខុសត្រូវធ្វើជាតំណាងឲ្យសាលាក្នុងមូលដ្ឋានរបស់ខ្លួនដោយត្រូវចែករំលែកការរៀនសូត្រ និងការយល់ដឹងរបស់ខ្លួន។

កម្មវិធី «ដំណើរទស្សនកិច្ចសិក្សាស្តីពី សន្តិភាពអន្លង់វែង» បង្ហាញពីចំណុចចាប់ផ្តើមនៃការងាររបស់មជ្ឈមណ្ឌលសន្តិភាព ឆ្ពោះទៅកាន់ការសម្រេចបាននូវវត្ថុបំណងរបស់មជ្ឈមណ្ឌល ក្នុងការលើកកំពស់សន្តិភាព ការអប់រំ និងសហគ្រាសសង្គម ដោយក្នុងនោះវត្ថុបំណងទាំងអស់ជួយជំរុញឲ្យគ្នាទៅវិញទៅមក។ តាមរយៈវត្ថុបំណងទាំងអស់នេះហើយ មជ្ឈមណ្ឌលសន្តិភាពនឹងក្លាយជាស្ថាប័ននាំមុខសម្រាប់ការអភិវឌ្ឍប្រកបដោយចេរភាពដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សាក្នុងប្រទេសកម្ពុជាក្នុងតំបន់ ក៏ដូចជាមជ្ឈដ្ឋានខាងក្រៅ។



អ៊ឹម ចែម(ខាងឆ្វេង) អង្គុយក្បែរ ឆាំង យុ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅប្រាសាទព្រះវិហារលើកំពូលភ្នំដងរែកដែលលាតសន្ធឹងនៅតាមព្រំប្រទល់កម្ពុជាថៃ។ អ៊ឹម ចែម ធ្លាប់ជាអតីតប្រធានស្រុកមួយដែលជាកន្លែងប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិតដោសារការសម្លាប់ភាពអត់ឃ្លាន និងភាពល្ហិតល្ហៃក្នុងអំឡុងសម័យខ្មែរក្រហម(១៩៧៥ដល់១៩៧៩)។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចោទប្រកាន់ អ៊ឹម ចែម ពីបទទទួលខុសត្រូវទៅលើបទឧក្រិដ្ឋកម្មទាំងអស់នោះ។ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ អ៊ឹម ចែម បានមកទស្សនាប្រាសាទព្រះវិហារជាលើកដំបូងក្នុងជីវិតរបស់គាត់ ដែលប្រាសាទនេះមានអាយុកាលមួយសហស្សវត្សរ៍។ ចាប់តាំងពីមានជម្លោះព្រំដែនជាមួយថៃលើដីនៅជុំវិញប្រាសាទព្រះវិហារមក អ៊ឹម ចែម និងអ្នកភូមិរបស់គាត់ជួយផ្តល់ជំនួយទាំងខាងស្មារតី និងសម្ភារឥតឈប់ឈរដល់ទៅកងទ័ពខ្មែរជួរមុខ។ គាត់និងប្រជាជនក្នុងភូមិដែលភូមិនេះមានចម្ងាយប្រហែល៩០គីឡូម៉ែត្រពីប្រាសាទព្រះវិហារដែលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារការវាយប្រហារថ្មីៗនេះបានសាមគ្គីគ្នានិងជួយគាំទ្រដល់ការវាយប្រហារតបតទៅនឹងការ លុកលុយរបស់ថៃ។ ដូចគ្នានឹងអ៊ឹម ចែម ដែរកងទ័ពខ្មែរដែលឈរជើងនៅទីតាំងជម្លោះមួយចំនួនធ្លាប់ធ្វើជាយោធាខ្មែរក្រហមព្រមទាំងមួយចំនួនទៀតធ្លាប់ជាកងជំនួយដែលបញ្ជូនចេញពីតំបន់របស់អ៊ឹម ចែម ផ្ទាល់ទៅកាន់សមរភូមិ។ យុទ្ធជនទាំងអស់ចាប់ផ្តើមប្តេជ្ញាចិត្តប្រយុទ្ធការ ៣ រ អធិបតេយ្យភាពរបស់កម្ពុជា។ បណ្ឌិត ចន ឆធើអរី បច្ចុប្បន្នគឺជាសាស្រ្តាចារ្យបង្រៀនផ្នែកនីតិអន្តរជាតិ និងនយោបាយនៅសាកលវិទ្យាល័យមីឈីហ្គេន និង ជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ម៉្យាងទៀតគាត់ក៏បានទៅទស្សនាប្រាសាទព្រះវិហារជាមួយគ្នាដែរ។ ទន្ទឹមគ្នានោះដែរគាត់ក៏មានប្រសាសន៍ថាតាមន័យនៃការផ្សះផ្សារដ្ឋាភិបាលថៃក្នុងន័យមួយបានកំពុងតែជួយរួមចំណែកដល់រដ្ឋាភិបាលកម្ពុជា។ បណ្ឌិត ចន ឆធើអរី យល់ឃើញថាការផ្សះផ្សាជាតិក្នុងកម្រិតដែលយើងមិនទាន់អាចសម្រេចបានពីមុនមកអាចនឹងសម្រេចទៅបានដោយសារការកើតមានជម្លោះព្រំដែនជាមួយថៃលើដីនៅជិត ប្រាសាទព្រះវិហារ។ អត្តសញ្ញាណរបស់ខ្មែរក្រហមត្រូវផ្លាស់ប្តូរ។ អ្នកទាំងអស់ហាក់បីដូចជាបានលុបបំបាត់ពាក្យថា «ក្រហម» ដោយឥឡូវចាត់ទុកខ្លួនឯងថាជាខ្មែរតែមួយ និងកំពុងតែប្រឆាំងការពារទឹកដីកម្ពុជាឱ្យរួចផុតពីការឈ្លានពានរបស់បរទេសយ៉ាងមានមោទនភាព។ រដ្ឋាភិបាលកម្ពុជាត្រេកអរចំពោះអតីតយោធាខ្មែរក្រហមដែលកំពុងការពារតំបន់ជម្លោះនិងប្រាសាទព្រះវិហារដូចគ្នានោះដែរប្រជាជនភាគច្រើនក៏សប្បាយចិត្តដែលមានយុទ្ធជនការពារប្រាសាទក្នុងរយៈពេលយូរអង្វែង។»

ចំណងជើង និងរូបថតដោយ៖ ជី ទេវិទ្ធ

រូបភាពខាងលើ៖ នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣ តុលាការយុត្តិធម៌អន្តរជាតិបានប្រកាសការបកស្រាយសាលក្រម ឆ្នាំ១៩៦២ ចំពោះជំលោះ ខ្មែរ ថៃ ទាក់ទងនឹងប្រាសាទព្រះវិហារនិងតំបន់នៅជុំវិញ។ប្រាសាទព្រះវិហារគឺជាប្រាសាទបុរាណបែបសាសនាហិណ្ឌូដែលត្រូវបានសាងឡើងក្នុងសម័យចក្រភពខ្មែរ ហើយប្រាសាទនេះមានទីតាំងស្ថិតនៅលើកំពូលភ្នំមួយកំពស់ ៥២៥ម៉ែត្រ នៅតំបន់ជួរភ្នំដងរែកក្នុងខេត្តព្រះវិហារនៃប្រទេសកម្ពុជា។ (ចម្ងាយពីប្រាសាទព្រះវិហារទៅកាន់ស្រុកអន្លង់វែងគឺ៧៨គីឡូម៉ែត្រ។ រូបថតដោយ អ៊ូចមករា)